# កម្មវិធីឃ្លាំមើលសវនាការសាលាក្ដីខ្មែរក្រហម




**Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center**

*...នៅពេលនោះ ប្តីប្រពន្ធមិនត្រូវដឹងការងារប្តីទេ។*
--សាក្សី **នឹម សែម**

## ផ្នែកទី១ ៖ ទិដ្ឋភាពទូទៅ

អង្គជំនុំជម្រះ បានបន្តដោះស្រាយបញ្ហានៃការសម្របសម្រួលពេលវេលាសវនាការ ដោយសារបញ្ហាសុខភាព និងភាពមានកម្រិតនៃការលះបង់សិទ្ធិមានវត្តមានរបស់ជនជាប់ចោទ **អៀងសារី** ។[1]ដូច្នេះ មានតែសាក្សីម្នាក់គត់ គឺអ្នកស្រី **នឹម សែម** (**TCW-៤៧៥**) ដែលបានផ្តល់សក្ខីកម្មនៅសប្តាហ៍នេះ។ អ្នកស្រី **នឹម សែម** ជាអ្នកចម្រៀង និងអ្នកអានសារព័ត៌មាន សម្រាប់ក្រសួងព័ត៌មាន និងឃោសនាការ។ អ្នកស្រីបានផ្តល់សក្ខីកម្មពីតួនាទីរបស់អ្នកស្រីនៅក្នុងបក្ស រចនាសម្ព័ន្ធរដ្ឋបាលនៅក្នុងក្រសួង មន្ទីរ៨៧០ ហើយនិងភាពខុសគ្នារវាងមន្ទីរ-ក មួយចំនួន នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ អ្នកស្រីបានបញ្ចប់សក្ខីកម្មរបស់អ្នកស្រីត្រឹមតែរយៈពេលមួយថ្ងៃ ហើយអង្គជំនុំជម្រះបានប្រកាសសម្រាកមួយសប្តាហ៍។ អង្គជំនុំជម្រះបានកំណត់បន្តកិច្ចដំណើរការនីតិវិធីវិញ នៅថ្ងៃចន្ទ ទី០១ ខែតុលា ឆ្នាំ២០១២។

## ផ្នែកទី២ ៖ ការសង្ខេបសក្ខីកម្មរបស់សាក្សី

អ្នកស្រី **នឹមសែម** [2] ជាសាក្សីស្ត្រីទី៣ នៅក្នុងកិច្ចដំណើរការសវនាការនេះ។ អ្នកស្រីមានអាយុ ៥៩ ឆ្នាំ ហើយជាស្ត្រីមេម៉ាយ ដែលមកពីស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។ បច្ចុប្បន្ន អ្នកស្រីជាកសិករ ប៉ុន្តែគាត់ធ្លាប់ជាអ្នកចម្រៀង និងជាភរិយាលោក **ខាន់ លីន** ហៅ **កែន** នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ លោក **ខាន់ លីន** ធ្លាប់បម្រើជាអង្គរក្សរបស់ **ប៉ុល ពត** និងជាប្រធានមន្ទីរ ៨៧០ ក្នុងអំឡុងពេលដែលរបបនោះធ្លាក់ចុះខ្សោយ។ សាក្សីបានផ្តល់សក្ខីកម្មត្រង់ៗពីបទពិសោធន៍របស់អ្នកស្រី នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។ យ៉ាងណាមិញ ដោយសារអ្នកស្រីមានតួនាទីជាកម្មាភិបាលថ្នាក់ទាប ហើយដោយសារការកន្លងទៅនៃពេលវេលា ធ្វើឲ្យការចងចាំព្រឹត្តិការណ៍នានារបស់អ្នកស្រី គឺមានកម្រិត។ ដោយសារមូលហេតុថា អ្នកស្រីមាន

ទំនាក់ទំនងតិចតួចជាមួយជនជាប់ចោទ ដូច្នេះ អ្នកស្រីមិនអាចចងចាំយ៉ាងលម្អិតអំពីរចនាសម្ព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់អ្នកស្រីបានឡើយ។

### ក. ប្រវត្តិរូប និងតួនាទីក្នុងចលនាបដិវត្តន៍

អ្នកស្រី **នឹម សែម** ដើមឡើយ មកពីឃុំពាម ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។ អ្នកស្រីបានរៀបរាប់ពីរបៀបដែលអ្នកស្រីបានរត់គេចខ្លួនចូលទៅក្នុងព្រៃជាមួយបងស្រីៗរបស់អ្នកស្រី ក្នុងឆ្នាំ១៩៨៦ ដោយសារតែភាពភ័យខ្លាចពីការចាប់ខ្លួន បន្ទាប់ពីរដ្ឋការភូមិចាប់បានសំបុត្ររបស់បងប្រុសអ្នកស្រី ដែលបានចូលរួមក្នុងចលនាបដិវត្តន៍។ ដំបូងឡើយ អ្នកស្រីគឺជាសិស្សពេទ្យនៅលើភ្នំឱរ៉ាល់ ខេត្តកំពង់ស្ពឺ។ តែក្រោយមកគេឲ្យអ្នកស្រីចូលក្រុមសិល្បៈវិញ ដើម្បីឲ្យអ្នកស្រីច្រៀងអប់រំតាមភូមិពីខ្លឹមសារបដិវត្តន៍។ អ្នកស្រីត្រូវបានគេបញ្ជូនទៅមន្ទីរ ស-៦ ជាកន្លែងសិល្បៈ សម្រាប់តំបន់ ៣០៤ នៅខេត្ត កំពង់ធំ។

សាក្សីជាសមាជិកនៃក្រុមសម្តែង ដែលអមដំណើរជាមួយ លោក **អៀង សារី** លោក **ខៀវ សំផន** លោកស្រី **អៀង ធីរិទ្ធ** លោក **សួង ស៊ីគឿន**[3] និងលោកស្រី **ទីវ អុល** ក្នុងកិច្ចដំណើរទស្សនកិច្ចទូតមួយ ទៅកាន់១៣ប្រទេស នៅដើមឆ្នាំ១៩៧៤។ ដោយមានការណែនាំពីលោក **អៀង សារី** អ្នកស្រីបានធ្វើដំណើរទៅកាន់ទីក្រុងហាណូយ ធ្វើជាអ្នកចម្រៀង សម្រាប់ប៉ុស្តិ៍វិទ្យុរណសិរ្សរួបរួមជាតិ។ ទោះបី អ្នកស្រីមិនប្រាកដ ប៉ុន្តែអ្នកស្រីបានរៀបរាប់ឈ្មោះលោកស្រី **អៀង ធីរិទ្ធ** និងស៊ូ គឺជាអ្នកដែលអាចទទួលខុសត្រូវស្ថានីយវិទ្យុនោះ។

បន្ទាប់ពីការរំដោះទីក្រុងភ្នំពេញ នៅក្នុងខែឧសភា ឆ្នាំ១៩៧៥ អ្នកស្រីបានធ្វើដំណើរទៅកាន់ទីក្រុងជាមួយនឹងលោកស្រី **អៀង ធីរិទ្ធ** ជាកន្លែងដែលអ្នកបានបម្រើការងារនៅក្នុងក្រសួងព័ត៌មាន និងឃោសនាការ។ ស្រដៀងគ្នាទៅនឹងភារកិច្ចរបស់អ្នកស្រីនៅទីក្រុងហាណូយ អ្នកស្រីបានបម្រើការងារជាអ្នកសម្តែង និងជាអ្នកអានសារព័ត៌មានឲ្យស្ថានីយវិទ្យុនៃរបបកម្ពុជាប្រជាធិបតេយ្យ ខណៈពេលមកដល់ទីក្រុងភ្នំពេញរបស់អ្នកស្រី។ ជាញឹកញាប់ អ្នកស្រីបានអានអត្ថបទជុំវិញប្រធានបទមួយចំនួន ដូចជា ការបរាជ័យនៃរបប **លន់ នល់** និងរបបចក្រពត្តិនិយមរបស់សហរដ្ឋអាមេរិក និងអត្ថបទដែលបានលើកទឹកចិត្តមនុស្សឱ្យសាងសង់ប្រឡាយ និងទំនប់។

នៅក្នុងខែសីហា ឆ្នាំ១៩៧៥ មេរបស់អ្នកស្រី បានរៀបចំអាពាហ៍ពិពាហ៍ឲ្យអ្នកស្រីជាមួយ លោក **លីន ហៅ កែន** ដែលមានតួនាទីជាអង្គរក្សរបស់ **ប៉ុល ពត**។ បន្ទាប់ពីរៀបការមក អ្នកស្រីក៏បានបន្តភារកិច្ចរបស់អ្នកស្រីនៅក្នុងក្រសួងព័ត៌មាន និងឃោសនាការ ប៉ុន្តែក្នុងឆ្នាំ១៩៧៦ អ្នកស្រីបានឈប់បម្រើការងារ ហើយបានប្តូរទៅកាន់មន្ទីរ ក-៨ ដើម្បីថែទាំកូនរបស់អ្នកស្រីវិញ។ អ្នកស្រីបានស្នាក់នៅក្នុងអង្គភាពនេះ ស្ទើរតែពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ។ បន្ទាប់ពីបានស្នាក់នៅមន្ទីរ ក-១១ រយៈពេលមួយខែ អ្នកស្រីមានជម្ងឺ ហើយនៅយប់មួយបានសម្រាកនៅមន្ទីរពេទ្យរបស់មន្ទីរក-៧ នៅពេលដែលអ្នកស្រីទៅសួរសុខទុក្ខប្តីរបស់អ្នកស្រី។ សាក្សីបានប្រាប់ថា សំណួរដែលសួរដោយប្តីរបស់អ្នកស្រីត្រូវបានចោទសួរអ្នកស្រីដដែលៗ គាត់ប្រាប់អ្នកស្រីថា អ្នកស្រីមានការជាប់ពាក់ព័ន្ធជាមួយនឹងចម្លើយសារភាព។ សាក្សីបានបន្ថែមទៀតថា កុំតែមានការធ្វើអន្តរាគមន៍ពីអ៊ំ **ប៉ុល ពត** មិនដូច្នោះទេ អ្នកស្រីត្រូវបានចាប់យកទៅសម្លាប់បាត់ហើយ។ អ្នកស្រីបានអះអាងពីការពិតនៃកិច្ចសម្ភាសន៍កន្លងទៅថ្មីៗនេះ[4] ហើយអ្នកស្រីបានរៀបរាប់ពីស្ថានភាពដ៏គ្រោះថ្នាក់របស់អ្នកស្រី បន្ទាប់ពីមានការចាប់ខ្លួនលោក **ហ៊ូ នឹម** ដោយអ្នកស្រីបានថ្លែងថា ៖

*លីន ជារៀងរាល់ថ្ងៃបានតំរាមកំហែងខ្ញុំ ដោយចោទសួរខ្ញុំថា តើ ហ៊ូ នឹម បាននិយាយនឹងបង្រៀនអ្វីខ្លះដល់ខ្ញុំ? លីន បាននិយាយថា មានគេចោទដាក់ខ្ញុំ។ ខ្ញុំដឹងថា ប្រសិនបើគេចាប់ខ្ញុំ ខ្ញុំនឹងត្រូវស្លាប់ហើយ។ តាមពិត លីន ចង់ឲ្យគេចាប់ខ្ញុំ ដើម្បីឲ្យគាត់រួចខ្លួន ប៉ុន្តែ ប៉ុល ពត មិនអនុញ្ញាតឲ្យគេចាប់ខ្ញុំទេ។*

យ៉ាងណាមិញ វាហាក់ដូចជាបានបង្ហាញថា អ្នកស្រីបានបន្តរស់នៅជាមួយប្ដីរបស់អ្នកស្រី បន្ទាប់ពីព្រឹត្តិការណ៍នេះបានកើតឡើង ហើយគាត់នៅតែបន្តរស់នៅជាមួយគ្នា បើទោះបីជារបបនេះបានដួលរលំទៅហើយ។

## ខ. រចនាសម្ព័ន្ធរដ្ឋបាល

សាក្សីបានផ្ដល់សក្ខីកម្មបន្តិចបន្តួចអំពីរចនាសម្ព័ន្ធរដ្ឋបាលនៃក្រសួងព័ត៌មាន និងឃោសនាការ និងរចនាសម្ព័ន្ធនៅក្រោមការដឹកនាំរបស់មន្ទីរ៨៧០។

### *ខ.១. ក្រសួងព័ត៌មាន និងឃោសនាការ*

យោងតាមសក្ខីកម្មរបស់អ្នកស្រី **នឹម សែម** លោក **ហ៊ូ នឹម** ជារដ្ឋមន្ត្រីនៃក្រសួងព័ត៌មាន និងឃោសនាការ ចាប់តាំងពីការចាប់ផ្ដើមនៃរបបកម្ពុជាប្រជាធិបតេយ្យ។ លោក **សៅ** ហៅ "**ទ្រា**" ជាប្រធានក្រុមសិល្បៈ ហើយក៏ជាអ្នកតែងទំនុកច្រៀងសម្រាប់បក្សផងដែរ។ យ៉ាងណាមិញ សាក្សីមិនអាចផ្ដល់ព័ត៌មានបន្ថែម ស្ដីពីរចនាសម្ព័ន្ធរដ្ឋបាលនៃក្រសួងបានទេ។

### *ខ.២. មន្ទីរ ៨៧០ និងមន្ទីរ ក*

សាក្សីបានអះអាងថា មន្ទីរក -៨ មន្ទីរ ក-៧ និងមន្ទីរ ក-១១ គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរ ៨៧០ ទាំងអស់ "មន្ទីរ ក ទាំងអស់ គឺនៅស្ថិតនៅក្រោមការដឹកនាំរបស់មន្ទីរ៨៧០ ទាំងអស់"។ សាក្សីបានប្រាប់ថា មន្ទីរ ក-៨ ជាកន្លែងដែលអ្នកស្រីបានរស់នៅស្ទើរតែពេញរបបកម្ពុជាប្រជាធិបតេយ្យហើយ មន្ទីរ ក-៨ នេះ ជាកន្លែងដាំបន្លែសម្រាប់ផ្គត់ផ្គង់នៅក្នុងអង្គភាព និងជាទីផ្សារដែលមិនមានឈ្មោះ សម្រាប់ជនបរទេស។ ភរិយា និងកូនៗរបស់អង្គរក្ស គឺត្រូវធ្វើការនៅទីនោះ ប៉ុន្តែដោយក្តីងឿយឆ្ងល់ អ្នកស្រី **នឹម សែម** បាននិយាយថា ដោយសារតែអ្នកស្រីមានបញ្ហាសុខភាព ដូច្នេះ អ្នកស្រីមិនបានធ្វើការងារនៅមន្ទីរ ក-៨ ទេ អ្នកស្រីគ្រាន់តែមើលថែកូនរបស់អ្នកស្រីប៉ុណ្ណោះ។ អ្នកស្រីបានរស់នៅទីនោះជាមួយក្រុមគ្រួសាររបស់អង្គរក្សដទៃទៀត ខណៈដែលប្ដីរបស់អ្នកស្រីស្នាក់នៅមន្ទីរក -១។

សាក្សី **នឹម សែម** បានបង្ហាញថា មន្ទីរក-១ និងមន្ទីរ ក-៣ គឺមានទីតាំងនៅកន្លែងដែលលោក **នួន ជា** លោក **ប៉ុល ពត** និងលោក **ខៀវ សំផន** ស្នាក់នៅ ដែលជាញឹកញាប់ មន្ទីរទាំងពីរត្រូវបានផ្លាស់ប្ដូរទីតាំងគ្នាទៅវិញទៅមក។ ពេលប្រមូលផលបន្លែ អ្នកស្រីបានឃើញភរិយារបស់លោក **នួន ជា** និងលោក **ខៀវ សំផន** នៅមន្ទីរ ក-១។

នៅពេលដែលមានការសួរដេញដោលពីតួនាទីរបស់ស្វាមីរបស់អ្នកស្រីនៅក្នុងរបបនោះ **នឹម សែម** បាននិយាយថា គាត់បានដឹងថា លោក **លីន** គឺជាអង្គរក្សរបស់ **ប៉ុល ពត** ឬនីរសារ ខណៈដែលពួកគេបានរៀបការជាមួយគ្នា ប៉ុន្តែអ្នកស្រីមិនបានដឹងពីការងារពិតប្រាកដដែលស្វាមីរបស់អ្នកស្រីធ្វើនោះទេ។ អ្នកស្រី

បាននិយាយផងដែរថា ប្ដីរបស់អ្នកស្រីបានធ្វើដំណើរទៅកាន់មន្ទីរក-៧ នៅក្នុងរបបនោះ ប៉ុន្តែអ្នកស្រីមិនបានដឹងទេថា តើប្ដីរបស់អ្នកស្រីបានធ្វើអ្វីខ្លះនៅទីនោះទេ ឬអ្វីទៅជាមុខងាររបស់អង្គភាពនោះ។ ដោយសារមានការចាប់ខ្លួនរបស់ **ប៉ង់** នៅឆ្នាំ១៩៧៨ **លីន** បានទទួលមុខងារជាប្រធានមន្ទីរ៨៧០ ឬមន្ទីរស-៧១ របស់គាត់វិញ ប៉ុន្តែអ្នកស្រីគឺមិនប្រាកដចិត្តទេថា តើលេខកូដទាំងពីរនេះ សំដៅទៅអង្គភាពដូចគ្នា ឬយ៉ាងណានោះ។

## គ. គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា

សាក្សី **នឹម សែម** មិនអាចចងចាំពីខ្លឹមសារនៃសេចក្ដីប្រកាស ឬមាគ៌ាបក្សកុម្មុយនីស្តកម្ពុជាដែលអ្នកស្រីបានអានតាមរយៈវិទ្យុផ្សព្វផ្សាយនោះទេ ហើយអ្នកស្រីបានលើកឡើងថា "មិនចាប់អារម្មណ៍" ចំពោះបញ្ហានេះទេ។ អ្នកស្រីមិនអាចនឹកឃើញ នូវអ្វីដែលសហព្រះរាជអាជ្ញាបានអានជូនអ្នកស្រីឡើយ ដូចជា "មហាលោតផ្លោះ មហាអស្ចារ្យ" "ការតស៊ូវណ្ណៈ" ឬ "យុទ្ធសាស្ត្ររបស់បក្ស"។ ទោះជាយ៉ាងណា សក្ខីកម្មរបស់អ្នកស្រី បានរៀបរាប់ខ្លះៗពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ទាក់ទិននឹងបទពិសោធន៍របស់អ្នកស្រីផ្ទាល់ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

### *គ.១. ការរៀបចំអាពាហ៍ពិពាហ៍*

សាក្សីបានទទួលស្គាល់ថា ការរៀបការរបស់អ្នកស្រីជាមួយលោក **លីន** [5] គឺត្រូវបានរៀបចំឡើងដោយ "អង្គការ"។ ចំពោះអ្នកស្រីផ្ទាល់ ពាក្យថា "អង្គការ" មានន័យថា "ជាអ្នកដឹកនាំហ្នឹងឯង"។ មេរបស់ប្ដីរបស់អ្នកស្រី បានស្នើសុំរៀបចំការរៀបការនេះទៅកាន់មេរបស់អ្នកស្រី គឺលោក **ហ៊ូនឹម** ។ នៅពេលមានការចង់ដឹងពីការយល់ឃើញរបស់អ្នកស្រីទាក់ទងនឹងការសម្រេចចិត្តនេះ គាត់បានឆ្លើយយល់ព្រម ដោយនិយាយថា "ស្រេចតែអង្គការទេ" ដូច្នេះ លោក **ហ៊ូ នឹម** ក៏យល់ព្រមរៀបការឲ្យទៅ។ អ្នកដឹកនាំ និងសមាជិកបក្សពីរបីរូប បានចូលរួមពិធីមង្គលការ ជំនួសឲ្យឪពុកម្ដាយរបស់ពួកគេ។ មិនមានពិធីសែនព្រេននៅក្នុងពិធីរៀបការនោះទេ ផ្ទុយទៅវិញ គូស្វាមីភរិយាបានស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅធម្មតា ហើយសរសេរជីវប្រវត្តិ (ជីវប្បវត្តិ) រួចចាប់ដៃគ្នា ហើយសូត្រថា "ប្ដេជ្ញាចិត្ត ហើយខំធ្វើការងារតែប៉ុណ្ណឹង"។ គូស្វាមីភរិយាផ្សេងៗទៀត គឺលោក **សៅ** និងប្រពន្ធរបស់គាតក៏បានរៀបការនៅក្នុងពិធី នោះផងដែរ។

### *គ.២. ការចាប់ខ្លួន និងការបាត់ខ្លួន*

នៅពេលដែលសាក្សី **នឹម សែម** ត្រូវបានសួរថា តើអ្នកស្រីបានដឹងពីការចាប់ខ្លួននានា នៅក្នុងមន្ទីរក-៨ ដែរឬទេ អ្នកស្រីបាននឹកឃើញថា ឈ្មោះ **យ៉ន** ជាអ្នកកាន់ឃ្លាំងនៅមន្ទីរ ក-៨ បានបាត់ខ្លួន។ ប៉ុន្តែអ្នកស្រីមិនបានឃើញការចាប់ខ្លួនគាត់ទៅដោយផ្ទាល់ភ្នែកនោះទេ។ អ្នកស្រីបានឮថា **ប៉ង់** ជាប្រធានមន្ទីរ ៨៧០ ដែលត្រូវបានចោទប្រកាន់ថា ជាជនក្បត់ ហើយត្រូវបានចាប់ខ្លួនក្រោយការចាប់ខ្លួនរបស់សហការីរបស់គាត់ឈ្មោះ **ភុំ**។ អ្នកស្រីក៏បានដឹងពីការចាប់ខ្លួនរបស់មេរបស់អ្នកស្រីគឺលោក **ហ៊ូ នឹម** និងលោក **សៅ** ដែលត្រូវបានចោទប្រកាន់ថា ជាភ្នាក់ងារ **សេ.អ៊ី.អា** (**CIA**) ហើយក៏ជាមូលហេតុដែលនាំឲ្យប្ដីរបស់អ្នកស្រីសួរអ្នកស្រីពីទំនាក់ទំនងរបស់អ្នកស្រីជាមួយនឹងថ្នាក់ដឹកនាំទាំងនេះ។ (សូមមើល ផ្នែកទី២.ក ខាងលើនេះ)

### *គ.៣. គោលការណ៍រក្សាការសម្ងាត់*

ផ្អែកតាមអ្នកស្រី **នឹម សែម** "ការរក្សាការសម្ងាត់នៅពេលនោះ គឺមិនឲ្យការងារអ្វីមួយៗ មិនឲ្យអ្នកផ្សេងដឹងក្រៅពីខ្លួនឯង"។ នៅពេលដែលអ្នកស្រីត្រូវបានសួរថា ប្រសិនជាប្ដីរបស់អ្នកស្រីបានពិភាក្សារបស់តួនាទីរបស់គាត់នៅក្នុងការស៊ើបអង្កេតជនក្បត់ អ្នកស្រីនិយាយថា "គាត់មិនដែលបានប្រាប់ផងៗ នៅពេលនោះ ប្ដីប្រពន្ធមិនត្រូវដឹងការងារប្ដីទេ"។

### ឃ. ការជាប់ពាក់ព័ន្ធជាមួយជនជាប់ចោទ

សាក្សី **នឹម សែម** បានផ្ដល់សក្ខីកម្មតែបន្តិចបន្តួចប៉ុណ្ណោះ ទាក់ទិនទៅនឹងជនជាប់ចោទទាំងបីរូប។ អ្នកស្រីបានចងចាំថា មុនពេលរបបកម្ពុជាប្រជាធិបតេយ្យ អ្នកស្រីបានឃើញលោក **នួន ជា** ម្ដង នៅពេលដែល មេដឹកនាំទាំងនោះផ្ដល់វគ្គអប់រំខាងនយោបាយ។ អ្នកស្រីបានបន្ថែមទៀតថា លោក **អៀង សារី** ហើយនិង លោក **ខៀវ សំផន** បានថ្លែងសុន្ទរកថា ក្នុងពេលដំណើរទស្សនកិច្ចរបស់ពួកគេទៅកាន់បរទេស ប៉ុន្តែអ្នកស្រីមិនអាចចងចាំពីខ្លឹមសារនៃសុន្ទរកថានោះបានទេ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អ្នកស្រី **នឹម សែម** បានឃើញ លោក **នួន ជា** នៅក្នុងមន្ទីរ ក-៣[6] គាត់កំពុងតែហូបអាហារជាមួយលោក **ខៀវ សំផន** និងប៉ុល ពត។ ទោះជាយ៉ាងណាក្ដី អ្នកស្រីមិនបានដឹងពីទំនាក់ទំនងរបស់លោក **នួន ជា** ទៅនឹងមន្ទីរ ៨៧០ទេ។

## ផ្នែកទី ៣ ៖ បញ្ហាច្បាប់ និងនីតិវិធី

បញ្ហាជាទូទៅដែលកើតមានឡើងនៅក្នុងពេលផ្ដល់សក្ខីកម្ម គឺត្រូវបានលើកឡើងក្នុងអំឡុងកិច្ចដំណើរការនីតិវិធី ដោយមានការចោទប្រកាន់ពីភាពមិនប្រក្រតីក្នុងការស៊ើបអង្កេត ដែលធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេតនាំឲ្យមានការចាប់អារម្មណ៍ពីសំណាក់អង្គជំនុំជម្រះសារជាថ្មីម្ដងទៀត។

### ក. ការស៊ើបអង្កេតដែលធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត

នៅក្នុងសំណួររបស់មេធាវីអន្តរជាតិការពារក្ដីឲ្យលោក **អៀង សារី** លោក **ម៉ៃខល កាណាវ៉ាស** *(Mr. Michael Karnavas)* បានបញ្ជាក់ពីកំហុសនីតិវិធីនៅក្នុងកិច្ចសម្ភាសន៍របស់អ្នកស្រី **នឹម សែម** ជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត។ មេធាវីការពារក្ដីបានលើកយកផ្នែកមួយនៃកិច្ចសម្ភាសន៍ ដែលសហចៅក្រមស៊ើបអង្កេត បានបង្ខំឲ្យសាក្សីប្រាប់ឈ្មោះអ្នកដែលបានធ្វើការជាមួយ **លីន** ហើយបានលើកឡើងពីកិច្ចសម្ភាសន៍ដែលមិនបានធ្វើកំណត់ហេតុនាព្រឹកមួយ ៖ "តើមីងដឹងទេ តើអ្នកណាធ្វើការជាមួយពូ **លីន** ដែលថា ឥឡូវនេះអ្នកហ្នឹងខ្លះស្លាប់ ក៏នៅរស់ ហើយគាត់សួរថាតើមានឈ្មោះអ្វី? ហើយគាត់ថា មីងប្រាប់ខ្ញុំព្រឹកមិញ ហើយព្រឹកមិញនេះគឺបានប្រាប់ឈ្មោះច្រើនណាស់"។ សាក្សី **នឹម សែម** បានទទួលស្គាល់ថា អ្នកស្រីបានផ្ដល់ព័ត៌មានឲ្យអ្នកស៊ើបអង្កេត នាព្រឹកថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៩ មុនចម្លើយរបស់អ្នកស្រីត្រូវបានថតចម្លងនៅពេលរសៀល។

ដូចគ្នាទៅនឹងសប្ដាហ៍មុនៗ គឺបានគូសបញ្ជាក់ពីការលើកឡើងនូវភាពមិនប្រក្រតីពីខាងក្រុមមេធាវីការពារក្ដី នៅក្នុងកិច្ចដំណើរការស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត។[7] ដូចគ្នាទៅនឹងសាក្សីរូបនេះ សាក្សីកាលមុនៗ គឺលោក **អឿន តាន** និងសាក្សីនង **សុផង់** ក៏បានធ្វើនូវកិច្ចសម្ភាសន៍ដែលមិនមានការធ្វើកំណត់ត្រា មុនពេលមានកំណត់ត្រាកិច្ចសម្ភាសន៍របស់ពួកគេផងដែរ ហើយនេះគឺជាបញ្ហាដែល

មេធាវីការពារក្តីរបស់លោក **អៀង សារី** បានលើកឡើងនៅក្នុងសំណើជាលាយលក្ខណ៍អក្សរ។[8] ខណៈដែលអង្គជំនុំជម្រះមិនទាន់បានសម្រេចទៅលើសំណើទាំងអស់នេះ ប៉ុន្តែវាបានសម្រេចដោយមានភាពលម្អៀងទៅលើការសន្មតថាជាការធម្មតា សម្រាប់កិច្ចដំណើរការស៊ើបសួររបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ដោយបានលើកឡើងនៅក្នុងសវនាការថា សំណួរទាំងឡាយណាដែលទាក់ទងទៅនឹងនីតិវិធីស៊ើបអង្កេត គួរណាតែលើកឡើងនៅក្នុងដំណាក់កាលស៊ើបអង្កេត។[9] ការធ្វើដូចនេះគឺស្របតាមវិធានផ្ទៃក្នុង ៧៦(៧) ដែលបានចែងថា "ដីកាដំណោះស្រាយ ត្រូវកែតម្រូវកំហុសនៃការមិនគោរពវិធានបញ្ញត្តិក្នុងការស៊ើបសួរ។ គ្មានបញ្ហាណាមួយដែលពាក់ព័ន្ធនឹងកំហុសនីតិវិធីបែបនេះ អាចត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូលឡើយ"។

## ខ. វិសាលភាពនៃសវនាការ និងសំណួរដែលមានការជាប់ពាក់ព័ន្ធ

មេធាវីអន្តរជាតិការពារក្តីរបស់លោក **នួន ជា** គឺលោក **អេនឌ្រូ អ៊ីនូហ្សុី** *(Mr. Andrew Ianuzzi)* បានលើកឡើងពីបញ្ហានៃវិសាលភាពនៃសំណួរដែលត្រូវបានអនុញ្ញាតឲ្យធ្វើការសាកសួរ នៅក្នុងវគ្គសវនាការមួយនេះ បន្ទាប់ពីការិយាល័យសហព្រះរាជអាជ្ញា បានផ្តោតទៅលើសំណួរមួយចំនួនស្តីពីការរៀបចំការរៀបការរបស់សាក្សី ដោយបានលើកទឡ្ហីករណ៍ថា សាក្សីត្រូវបានកោះហៅឲ្យមកផ្តល់សក្ខីកម្មពីរចនាសម្ព័ន្ធនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ សហព្រះរាជអាជ្ញាអន្តរជាតិ **វ៉ាំងសង់ វ៉ាយឌ៍ ដេស្មាឯល** *(Vincent De Wilde d'ESTMAEL)* បានឆ្លើយតបថា សំណួរដែលទាក់ទងទៅនឹងការរៀបអាពាហ៍ពិពាហ៍របស់សាក្សីជាមួយប្តីរបស់គាត់ និងទំនាក់ទំនងរបស់ពួកគេ គឺមានការជាប់ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋបាល។ អង្គជំនុំជម្រះ បានអនុញ្ញាតឲ្យសួរសំណួរបន្ថែមលើបញ្ហានេះ ដោយបានថ្លែងថា សក្ខីកម្មគឺមានភាពទាក់ទិនទៅនឹងសាក្សីផ្ទាល់ និងការងារនៅមន្ទីរ ៨៧០។ យ៉ាងណាមិញ អង្គជំនុំជម្រះបានរំលឹកភាគីទាំងអស់ថា បញ្ហាអំពីការរៀបការដោយបង្ខំ គឺមិនស្ថិតនៅក្នុងវគ្គសវនាការនៃសំណុំរឿង ០០២/០១ ទេ។

បញ្ហាដូចគ្នានេះដែរ បានកើតឡើងសាជាថ្មីម្តងទៀត ក្នុងអំឡុងពេលនៃការសាកសួរដេញដោលរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីលោកស្រី **អេលីហ្សាបេត ស៊ីម៉ុនណូហ្វត** *(Ms. Elisabeth Simonneau-Fort)* ដោយមេធាវីការពារក្តី **អ៊ីនូហ្សុី** បានធ្វើការជំទាស់ថា សំណួរទូទៅស្តីពីការរៀបការ និងការមើលថែទាំកូន នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺស្ថិតនៅក្រៅវិសាលភាពនៃសវនាការវគ្គនេះ។ លោកស្រី **ស៊ីម៉ុន ណូហ្វត** បានឆ្លើយតបថា សំណួរដែលមានភាពទាក់ទងទៅនឹងរចនាសម្ព័ន្ធ និងរបៀបដែលប្រជាជនរស់នៅផ្សេងៗគ្នានៅក្នុងរបបនោះ គឺមានការជាប់ពាក់ព័ន្ធនឹងសំណុំរឿងនេះ។ ជាការគួរឲ្យចាប់អារម្មណ៍ ពេលដែលអង្គជំនុំជម្រះបានថ្លែងថា សំណួរគឺ "យ៉ាងណាក៏ត្រូវមានការជាប់ពាក់ព័ន្ធទៅនឹងអង្គហេតុដែលចោទប្រកាន់ ប្រឆាំងនឹងជនជាប់ចោទ" ប៉ុន្តែវានៅតែអនុញ្ញាតឲ្យសាក្សីឆ្លើយតបទៅនឹងសំណួរ "ប្រសិនបើវាស្ថិតនៅក្នុងការដឹងឮរបស់សាក្សី"។

អំឡុងពេលនៃការសាកសួរដេញដោលរបស់លោក **អ៊ីនូហ្សុី** គាត់បានសួរសាក្សីថា តើសាក្សីធ្លាប់បានដឹងឮពីគម្រោង ក-៥ របស់រដ្ឋាភិបាលនៅក្នុងទសវត្សរ៍ទី៨០ដែរឬទេ។[10] ការសួរបែបនេះ បានធ្វើឲ្យមានការជំទាស់ភ្លាមៗពីសហព្រះរាជអាជ្ញា **វ៉ាំងសង់ វ៉ាយឌ៍ ដេស្មាឯល** ដោយបានអះអាងថា សំណួរដែលទាក់ទងទៅនឹងមនុស្សសាស្ត្រ (នៅម៉ាឡៃ) គឺត្រូវបានសម្រេចដោយអង្គជំនុំជម្រះរួចហើយថា មិនជាប់ពាក់ព័ន្ធទៅ

នឹងដីកាដំណោះស្រាយនោះទេ។ ជាកិច្ចឆ្លើយតប លោក **អ៊ីនូហ្ស៊ី** បានលើកហេតុផលថា សំណួររបស់គាត់គឺមានការជាប់ពាក់ព័ន្ធទៅនឹងការស្លាប់ ដែលនាំឲ្យមានការចោទប្រកាន់ប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យ ដោយមនុស្សរាប់ពាន់នាក់បានស្លាប់ ហើយវាក៏ជាលទ្ធផលនៃផែនការ ក-៥ នោះដែរ។ យ៉ាងណាមិញ អង្គជំនុំជម្រះបានសម្រេចការជំទាស់មានប្រសិទ្ធភាព ដោយចាត់ទុកថា សំណួររបស់មេធាវីគឺមិនមានការជាប់ពាក់ព័ន្ធទៅនឹងអង្គហេតុនៅចំពោះមុខតុលាការទេ។

### គ. សំណួរបែបសន្និដ្ឋាន

អំឡុងពេលនៃការសាកសួររបស់គាត់ លោក **អ៊ីនូហ្ស៊ី** បានលើកឡើងពីការបដិសេធរបស់សាក្សី **ជាម**[11] ហើយបានសួរសាក្សីថា តើអ្នកស្រីមានយោបល់អ្វីខ្លះទេ "ហេតុអ្វីបានជា **ជាម** បានធ្វើដូច្នេះ"។ ទោះជាយ៉ាងណាក៏ដោយ ការសួរបែបនេះ ធ្វើឲ្យមានការជំទាស់ពីភាគីសហព្រះរាជអាជ្ញា ដោយសម្អាងថា សំណួរបែបនេះ គឺស្នើសុំឲ្យសាក្សីឆ្លើយព្រាវៗ គឺមិនសមហេតុផលទេ។ លោក **អ៊ីនូហ្ស៊ី** បានតវ៉ាថា គាត់ជឿជាក់ថា សំណួរនេះគឺមានការជាប់ពាក់ព័ន្ធយ៉ាងខ្លាំង ពីព្រោះលោក **វ៉ាចាម តុន** ជាបុគ្គលម្នាក់ដែលសាក្សីបានស្គាល់ ហើយក៏ជាបុគ្គលដែលសាធារណជនស្គាល់ច្រើននៅក្នុងតំបន់របស់អ្នកស្រីផងដែរ។ លោក **វ៉ាចាម តុន** គឺត្រូវបានទទួលរងឥទ្ធិពលយ៉ាងពិតប្រាកដ ពីរដ្ឋមន្ត្រីក្រសួងការបរទេសលោក **ហោ ណាំហុង** ក្នុងការច្រានចោលសក្ខីកម្មរបស់គាត់។ ការជំទាស់ត្រូវបានចាត់ទុកថាគ្មានប្រសិទ្ធិភាព ហើយសាក្សីត្រូវបានណែនាំមិនឲ្យឆ្លើយតបនឹងសំណួរនោះទេ។

## ផ្នែកទី ៤៖ ការគ្រប់គ្រងសវនាការ

បញ្ហាសុខភាពរបស់ជនជាប់ចោទ **អៀង សារី** បានបន្តផ្តល់ការប្រឈមមួយ ដល់អង្គជំនុំជម្រះក្នុងការរៀបចំកាលវិភាគនៃកិច្ចដំណើរការនីតិវិធី ជាហេតុបណ្តាលឲ្យមានសវនាការតែមួយថ្ងៃគត់ ដែលបានប្រព្រឹត្តឡើង នៅក្នុងសប្តាហ៍នេះ។

### ក. វត្តមាន

***វត្តមានរបស់ជនជាប់ចោទ*** ៖ មានតែជនជាប់ចោទ **ខៀវ សំផន** និង **នួន ជា** ទេ ដែលមានវត្តមាននៅក្នុងកិច្ចដំណើរការនីតិវិធី ប៉ុន្តែក្រោយមក ពួកគេបានបន្តចូលរួមសវនាការពីបន្ទប់ឃុំឃាំង (នៅក្រោមបន្ទប់សវនាការ)របស់ពួកគេ នៅវគ្គទីពីរនាពេលរសៀល។ ជនជាប់ចោទ **អៀង សារី** គឺនៅតែអវត្តមានពីក្នុងបន្ទប់សវនាការ ដោយសារតែគាត់បានបន្តការព្យាបាលនៅឯមន្ទីរពេទ្យ ប៉ុន្តែគាត់បានបោះបង់សិទ្ធិមានវត្តមាននៅក្នុងកិច្ចដំណើរការនីតិវិធីរបស់គាត់ ក្នុងពេលការផ្តល់សក្ខីកម្មរបស់សាក្សី **នឹម សែម**។

***វត្តមានរបស់មេធាវីការពារក្តី*** ៖ ជនជាប់ចោទទាំងអស់ត្រូវបានតំណាងដោយមេធាវីការពារក្តីរបស់ពួកគេ ប៉ុន្តែមានការកត់សម្គាល់ឃើញថា មេធាវីអន្តរជាតិការពារក្តីរបស់ជនជាប់ចោទ **ខៀវ សំផន** គឺអវត្តមាន ដោយសារមូលហេតុផ្ទាល់ខ្លួន។

***វត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណី*** ៖ កៅអីដែលទុកបម្រុងឲ្យដើមបណ្តឹងរដ្ឋប្បវេណីគឺពេញទាំងអស់សម្រាប់សវនាការ នៅក្នុងសប្តាហ៍នេះ។

**វត្តមានរបស់សាធារណជន៖**

| ថ្ងៃខែឆ្នាំ | ពេលព្រឹក | ពេលរសៀល |
|---|---|---|
| ថ្ងៃអង្គារ ២៥/០៩/១២ | ប្រជាពលរដ្ឋ ២៥០នាក់ មកពីខេត្ត ព្រៃវែង ហើយ និងអ្នកអង្កេតការជនបរទេស ២០នាក់ | ប្រជាពលរដ្ឋ ១០០នាក់ មកពីខេត្ត តាកែវ ហើយ និងអ្នកអង្កេតការជនបរទេស ១០នាក់ |

## ខ. ការគ្រប់គ្រងពេលវេលា

បញ្ហាសុខភាពរបស់ជនជាប់ចោទ **អៀង សារី** គឺមានភាពចាំបាច់សម្រាប់ការសម្រាកព្យាបាលរបស់គាត់ នៅឯមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ចាប់តាំងពីថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១២ មកម្ល៉េះ។ ទោះបីជា ជនជាប់ចោទបានបង្ហាញឆន្ទៈយ៉ាងច្បាស់លាស់ ក្នុងការបោះបង់សិទ្ធិមានវត្តមានរបស់គាត់នៅក្នុងកិច្ចដំណើរការនីតិវិធីចំពោះសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនក៏ដោយ[12] ប៉ុន្តែការជូនដំណឹងក្នុងរយៈពេលខ្លីបានធ្វើឲ្យពេលវេលាសម្រាប់ការចូលរួមសវនាការរបស់សាក្សីទាំងនេះ ក្លាយទៅជាបញ្ហាប្រឈមសម្រាប់អង្គជំនុំជម្រះ។ មានតែអ្នកស្រី **នឹម សែម** ម្នាក់គត់ ដែលអាចផ្តល់សក្ខីកម្ម ក្នុងសប្តាហ៍នេះ។ នៅពេលដែលសហព្រះរាជអាជ្ញា និងមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានផ្តល់ពេលវេលាពេញមួយថ្ងៃ ដើម្បីសាកសួរសំណួរទៅកាន់សាក្សី តែពួកគេបែរជាបញ្ចប់ការសាកសួរដេញដោលរបស់ពួកគេ មុនពេលវេលាដែលបានកំណត់ទុក។ ដោយឡែក ក្រុមមេធាវីការពារក្តី មានតែពីរបីសំណួរតែប៉ុណ្ណោះសម្រាប់ធ្វើការសាកសួរ ហើយចំណាយពេលវេលាតិចជាងមួយវគ្គនៃសវនាការ។ ហេតុដូច្នេះហើយ ដោយពុំមានសាក្សីបម្រុង អង្គជំនុំជម្រះក៏បានសម្រេចសម្រាកកិច្ចដំណើរការនីតិវិធីសវនាការ ពេញមួយសប្តាហ៍។

## គ. ឥរិយាបទក្នុងបន្ទប់សវនាការ

ការរៀបចំឡើងវិញនូវការផ្តល់សក្ខីកម្មឲ្យមានភាពសមរម្យ សម្រាប់ការសាកសួរដេញដោលរបស់មេធាវីការពារក្តី ត្រូវបានលើកឡើងនៅសប្តាហ៍នេះ។ នៅក្នុងវគ្គនៃការសាកសួរអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ស្តីពីការចាប់បង្ខំរៀបការ សហព្រះរាជអាជ្ញាអន្តរជាតិ **វ៉ាំងសង់ វ៉ាយដ៍** បានសួរទៅកាន់សាក្សីថា "បើសិនជាខ្ញុំយល់មិនច្រឡំទេ ទាក់ទងនឹងការរៀបការនេះគឺថា បក្សជាអ្នករៀបចំទាំងអស់តែម្តង តើត្រឹមត្រូវដែរឬទេ?" សំណួរនេះបានធ្វើឲ្យមានការជំទាស់ភ្លាមៗពីលោកមេធាវី **កាណាវ៉ាស** ដែលបានតវ៉ាថា សំណួរនេះគឺជា "សំណួរនាំមុខ និងផ្តល់ចម្លើយដល់សាក្សី" ហើយវាមិនមាននៅក្នុងសក្ខីកម្មរបស់សាក្សីទេ។ លោក **កាណាវ៉ាស** បានបន្ថែមទៀតថា "សហព្រះរាជអាជ្ញាហាក់ដូចជាសួរសំណួរដែលពាក់ព័ន្ធនឹងអង្គហេតុ ដែលមិនមែនជាការឆ្លើយជាភស្តុតាងពីសាក្សី" ហើយមិនមានការបញ្ជាក់ច្បាស់លាស់ទេ។ យ៉ាងណាមិញ មុននឹងអង្គជំនុំជម្រះបានសម្រេចលើការជំទាស់ សហព្រះរាជអាជ្ញា **វ៉ាំងសង់ វ៉ាយដ៍** បានរៀបចំនូវសំណួរឡើងវិញ ហើយថែមទាំងបានបញ្ឈប់ការលើកទឡ្ហីករណ៍បន្ថែមលើបញ្ហានេះផងដែរ។

ក្រោយមកទៀត លោក **អ៊ីនូហ្ស៊ី** បានជំទាស់ទៅនឹងសេចក្តីថ្លែងការណ៍សារជាថ្មីរបស់សហព្រះរាជអាជ្ញា **វ៉ាំងសង់ វ៉ាយដ** ដែលបាននិយាយថា "លោក នួន ជា បានបង្រៀនវគ្គបណ្តុះបណ្តាលនយោបាយ" ជំនួសពាក្យរបស់សាក្សី ដែលថា "នួន ជា បានផ្តល់វគ្គបណ្តុះបណ្តាល"។ លោក **អ៊ីនូហ្ស៊ី** បានថ្លែងថា មេធាវីប្រឆាំងគឺ "កំពុងតែបង្ហាញភស្តុតាង" ទាក់ទងនឹងសហព្រះរាជអាជ្ញា **វ៉ាំងសង់ វ៉ាយដ** ដែលបានលើកឡើងថា

នេះគឺ "ជាការលេងពាក្យសម្តី" ហើយមិនមែនជាសំណួរដ៏ចម្បងរបស់គាត់ទេ ព្រោះមានបំណងចង់ដឹងថា តើសាក្សីបានជួបលោក នួន ជា ម្តងទៀតនៅសម័យកម្ពុជាប្រជាធិបតេយ្យមែនដែរឬទេ។ នៅត្រង់ចំណុចនេះ អង្គជំនុំជម្រះ បានយល់ឃើញថា ការជំទាស់គឺមិនមានហេតុផលទេ ដោយមិនមានការបកស្រាយពីការរៀបរាប់សាឡើងវិញនៃសេចក្តីថ្លែងការណ៍របស់សាក្សី។

### ឃ. បញ្ហាបកប្រែ និងបច្ចេកទេស

បញ្ហាបច្ចេកទេស ត្រូវបានកត់សម្គាល់តាំងពីកិច្ចចាប់ផ្តើមដំបូងនៃសវនាការ ក្នុងសប្តាហ៍នេះ។ វាំងននបន្ទប់សវនាការបានបើក ហើយភាគីទាំងអស់បានចូលទៅក្នុងបន្ទប់សវនាការនៅម៉ោង ០៩:០២ ព្រឹក ប៉ុន្តែវាហាក់ដូចជាបានបង្ហាញឲ្យឃើញថា ចៅក្រមមិនទាន់រួចរាល់ដើម្បីចូលក្នុងបន្ទប់សវនាការនៅឡើយទេ។ ប្រហែលមួយនាទីក្រោយមក សាធារណជនត្រូវបានណែនាំឲ្យចូលទៅកន្លែងអង្គុយរបស់ពួកគេវិញ ហើយទូរទស្សន៍ផ្សព្វផ្សាយត្រូវបានកាត់ផ្តាច់។ ប្រហែលជាពីរបីនាទីក្រោយមក ទូរទស្សន៍ត្រូវបានចាក់ផ្សាយឡើងវិញ ហើយសវនាការបានចាប់ផ្តើមជាផ្លូវការ។

ពេលជិតបញ្ចប់សវនាការវគ្គទីមួយ បញ្ហាបច្ចេកទេសបន្តិចបន្តួចនៃឧបករណ៍សំឡេង បានកើតឡើង ដោយអ្នកបកប្រែបាននិយាយថា គាត់មិនអាចស្តាប់ឮសំឡេងរបស់សហព្រះរាជអាជ្ញាបានទេ។ ដោយមិនមានការប្រកាសពីក្រុមការងារបកប្រែ អង្គជំនុំជម្រះបានក្រោកឈរ ហើយក៏ចាកចេញពីបន្ទប់ សវនាការជាសញ្ញាប្រាប់ថា បញ្ចប់វគ្គសវនាការទីមួយ។ បញ្ហាបកប្រែតិចតួចក៏ត្រូវបានកត់សម្គាល់ឃើញផងដែរ ប៉ុន្តែវាមិនបានប៉ះពាល់ដល់ប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធីនោះទេ។

### ង. តារាងពេលវេលា

| កាលបរិច្ឆេទ | ចាប់ផ្តើម | សម្រាកពេលព្រឹក | អាហារថ្ងៃត្រង់ | សម្រាកពេលរសៀល | ផ្អាកសវនាការ | រយៈពេលសវនាការសរុប |
|---|---|---|---|---|---|---|
| ថ្ងៃអង្គារ ២៥/០៩/១២ | ៩:០៧ | ១០:២៤-១០:៤៤ | ១២:០១-១៣:៣២ | ១៤:៣៧-១៤:៥៦ | ១៦:០៨ | ៤ម៉ោង និង ៥១ នាទី |
| *ចំនួនម៉ោងជាមធ្យមក្នុងសវនាការមួយវគ្គ ៖ ៤ម៉ោង និង៥១នាទី*<br>*ចំនួនម៉ោងសរុបក្នុងសប្តាហ៍នេះ ៖ ៤ម៉ោង និង៥១នាទី*<br>*ចំនួនសរុបនៃ ម៉ោង ថ្ងៃ និងសប្តាហ៍ ៖ ៤៨០ម៉ោង និង១២នាទី* | | | | | | |
| *សវនាការសុរប ១១០ថ្ងៃ និង៣៣សប្តាហ៍* | | | | | | |

**Unless specified otherwise,**

- the documents cited in this report pertain to *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* before the ECCC;
- the quotes are based on the personal notes of the trial monitors during the proceedings;
- the figures in the *Public Attendance* section of the report are only approximations; and
- photos are courtesy of the ECCC.

**Glossary of Terms**

| | |
|---|---|
| Case 001 | *The Case of Kaing Guek Eav alias "Duch"*(Case No. 001/18-07-2007-ECCC) |
| Case 002 | *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* (Case No. 002/19-09-2007-ECCC) |
| CPC | Code of Criminal Procedure of the Kingdom of Cambodia (2007) |
| CPK | Communist Party of Kampuchea |
| CPLCL | Civil Party Lead Co-Lawyer |
| DK | Democratic Kampuchea |
| ECCC | Extraordinary Chambers in the Courts of Cambodia (also referred to as the Khmer Rouge Tribunal or "KRT") |
| ECCC Law | Law on the Establishment of the ECCC, as amended (2004) |
| ERN | Evidence Reference Number (the page number of each piece of documentary evidence in the Case File) |
| FUNK | National United Front of Kampuchea |
| GRUNK | Royal Government of National Union of Kampuchea |
| ICC | International Criminal Court |
| ICCPR | International Covenant on Civil and Political Rights |
| ICTR | International Criminal Tribunal for Rwanda |
| ICTY | International Criminal Tribunal for the former Yugoslavia |
| IR | Internal Rules of the ECCC Rev. 8 (2011) |
| KR | Khmer Rouge |
| OCIJ | Office of the Co-Investigating Judges |
| OCP | Office of the Co-Prosecutors of the ECCC |
| RAK | Revolutionary Army of Kampuchea |
| VSS | Victims Support Section |
| WESU | Witness and Expert Support Unit |

EAST-WEST CENTER

AIJI TRIAL MONITORING

WCSC WAR CRIMES STUDIES CENTER UNIVERSITY OF CALIFORNIA, BERKELEY

*AIJI is a collaborative project between the East-West Center, in Honolulu, and the War Crimes Studies Center, university of California, Berkeley. Since 2003, the two Centers have been collaborating on projects relating to the establishment of justice initiatives and capacity-building programs in the human rights sector in South-East Asia. The Program is funded by the open Society Foundation, the Foreign Commonwealth Office of the British Embassy in Phnom Penh, and the Embassy of Switzerland in Bangkok. This issue of KRT Trial Monitor was authorized by Princess B. Principle, Sovanna Sek, Kimsan Soy, and Peneloe Van Tuyl, as part of AIJI's KRT Trial monitoring and Community Outreach Program. KRT Trial Monitor reports on Case 002 are available at <www.krtmonitor.org>, and at the websites of the East-West Center and the War Crimes Studies Center.

[1] In accordance with Internal Rules 81 (1) and Articles 14 (1) and 14 (3) (d) of the international Covenant for Civil and Political Rights, Accused Ieng Sary issued a limited Waiver, agreeing to waive his direct presence in the courtroom only for 1 civil party and 7 witnesses, including the current witness Noem Sem (TCW-475). He explicitly stated that he is not waiving his right to be present for other witnesses. This necessitated adjustments in the trial schedule, with the Chamber seeking to present witnesses for whom Ieng Sary executed a waiver. See Ieng Sary. "Limited Waiver" (18 September 2012). E229. Due to his extended stay in the hospital, he subsequently issued another Limited Waiver for 11 additional witness and 7 civil parties. See Ieng Sary. "Limited Waiver" (1 October 2012). E237.

[2] Noem Sem was questioned by counsels in the following order: National Prosecutor Chan Dararasmey, International Prosecutor Mr. Vincent de Wilde D'Estmael, Civil Party National Counsel Lor Chunthy, CPLCL Elisabeth Simonneau-Fort, Khieu Samphan national counsel Kong Sam Onn, Nuon Chea international counsel Andrew Lanuzzi, and Ieng Sary international counsel Michael Karnavas.

[3] Mr. Suong Sikoeun, an intellectual and an MFA cadre during DK also provided testimony before the Trial Chamber. Se Case 002 KRT Trial Monitor. Issue No. 31, hearing on Evidence Week 26 (6-9 August 2012). 1-6. Case 002 KRT Trial Monitor. Issue No. 32, Hearing on Evidence Week 27 (13-16 August 2012). 4-7. Case 002 KRT Trial Monitor. Issue No. 33, Hearing on Evidence Week 28 (20-23 August 2012). 1-3.

[4] The interview with Noem Sem, quoted into the record by the OCP, appeared to have been conducted in July 2005 by a member of SOAS or the School of Oriental and African Studies, University of London.

[5] The Witness said she only knew Lin briefly prior to their marriage; he attended one of their art performances with Pol Pot.

[6] Noem Sem initially stated during her testimony that she saw Nuon Chea at K-3 during a training session. She later stated that she did not attend by any study sessions and she only visited her husband in K-3.

[7] Case 002 KRT Trial Monitor. Issue No. 26, Hearing on Evidence Week 21 (11-14 June 2012). 10-11. Case 002 KRT Trial Monitor. Issue No. 35, Hearing on Evidence Week 30 (3-6 September 2012). 6-7.

[8] See The Defense for Ieng Sary. "Ieng Sary's Request that the Trial Chamber seek clarification from the OCIJ as to the Existence of any Record Relating to the Questioning of Witness Oeun Tan on 8 October 2008" (29 August 2012). E224. The Defense for Ieng Sary. "Ieng Sary's Request that the Trial Chamber Seek Clarification from the OCIJ as to the questioning of the Witness Norng Sophang on 17 February 2009 and Summon the OCIJ investigators to Give Evidence Regarding the Interview" (27 September 2012). E.234

[9] See Case 002 KRT Trial Monitor. Issue No. 35, Hearing on Evidence Week 30 (3-5 September 2012). 7-8.

[10] According to Ianuzzi, the K-5 project involved "landmines and possibly many deaths from malaria in the1980s." This topic appeared to be in relation to the Nuon Chea Defense Team's assertion that the death toll estimates alleged against the Khmer Rouge during the period of 1975-79 was caused by other factors such as the K-5 project.

[11] Cheam, also known as Rochoem Ton or Phy Phuon, was a former Pol Pot bodyguard and MFA cadre who testified earlier before the Trial Chamber. However subsequent to this testimony, he issued a written retraction on his statement regarding current Foreign Affairs Minister Hor Namhong's connection with BoengTrabek. See Case 002 KRT Trial Monitor. Issue No. 32, Hearing on Evidence Week 27 (13-16 August 2012). 11-12. Case 002 KRT Trial Monitor. Issue No. 30, Hearing on Evidence Week 25 (30-31 July, 1-2 August 2012). 3.

[12] Ibid, at footnote 1.